**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ១៨០០......សហវ.....

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ [illegible] ឆ្នាំ ២០០៦

# ប្រកាស

## ស្តីពី

## ការកែសម្រួលការអនុវត្តសេវាអធិការកិច្ចទំនិញមុនពេលផ្ទុក

## ទេសរដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការចាត់តាំងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុន BIVAC International ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៦ ស្តីពីសេវាអធិការកិច្ចមុនពេលផ្ទុក
- បានឃើញប្រកាសលេខ ១៥៤ សហវ.ប្រក ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីការអនុវត្តន៍សេវាអធិការកិច្ចទំនិញមុនពេលផ្ទុក
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 ; Fax : 855-23-427 798

**សម្រេច :**

**ប្រការ ១ :** ត្រូវបានកែសម្រួលការដាក់ពិន័យជាទឹកប្រាក់ស្មើនឹង ១០% (ដប់ភាគរយ) នៃតម្លៃទំនិញសរុបគិតជា CIF ចំពោះក្រុមហ៊ុន ឬបុគ្គលទាំងឡាយណាដែលខកខានពុំបានមកសុំធ្វើអធិការកិច្ចទំនិញមុនពេលផ្ទុកនូវរាល់មុខទំនិញ លើកលែងតែមុខទំនិញដែលមានចែងនៅក្នុងជំពូកទី ២ ប្រការ ៣ ក្នុងឧបសម្ព័ន្ធនៃប្រកាសលេខ ១៥៤ សហវ.គរ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការអនុវត្តន៍សេវាអធិការកិច្ចទំនិញមុនពេលផ្ទុក ។

**ប្រការ ២ :** ប្រកាសទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៣ :** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ព្រមទាំងអង្គភាពពាក់ព័ន្ធនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឲ្យមានប្រសិទ្ធភាពចំពោះទំនិញប្រភេទដូចខាងលើ ដែលផ្ទុកចូលមធ្យោបាយដឹកជញ្ជូនឯបរទេសដើម្បីនាំចូលមកមកព្រះរាជាណាចក្រកម្ពុជាចាប់ពីថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៧ នេះតទៅ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ក្រសួងមហាផ្ទៃ
- ក្រសួងពាណិជ្ជកម្ម
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- គ្រប់សាលាខេត្តក្រុង
- ទីចាត់ការគយ និងរដ្ឋាករ
- សភាពាណិជ្ជកម្មរាជធានីភ្នំពេញ
- ការិយាល័យទំនាក់ទំនងក្រុមហ៊ុន BIVAC International នៅកម្ពុជា
- ឯកសារ - កាលប្បវត្តិ